ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងរៀបចំផែនការ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថ្នាលទូរទស្សន៍ឌីជីថលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៣/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧០អនក្រ.បក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៧១អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍នៃក្រសួងព័ត៌មាន
- យោងសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសរៀបចំផែនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថ្នាលទូរទស្សន៍ឌីជីថលជាតិ ដើម្បីផ្លាស់ប្តូរការផ្សាយទូរទស្សន៍ពីប្រព័ន្ធអាណាឡូកទៅជាប្រព័ន្ធឌីជីថលនៅព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ខៀវ កាញារីទ្ធ** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | ប្រធាន |
| ២- ឯកឧត្តម **វង្សី វិស្សុត** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ទីម គុណាវឌ្ឍន៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤- ឯកឧត្តម | **លឹម ឌុន្នី** | អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងធនធានវិសាលគមន៍ប្រេកង់វិទ្យុ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| ៥- ឯកឧត្តម | **ផុស សុវណ្ណ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍នៃក្រសួងព័ត៌មាន | អនុប្រធានអចិន្ត្រៃយ៍ |
| ៦- ឯកឧត្តម | **សុខ ប្រសិទ្ធិ** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៧- ឯកឧត្តម | **លី ម៉ាន់ហុខ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងព័ត៌មាន | សមាជិក |
| ៨- ឯកឧត្តម | **នុត មូផាន់** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៩- ឯកឧត្តម | **សំបូរ វណ្ណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១០-ឯកឧត្តម | **ឃឹម ឌុន្នី** | អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ១១-លោកជំទាវ | **ឆន ណាវី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ | សមាជិកា |
| ១២-ឯកឧត្តម | **សាន ពុទ្ធារី** | ទីប្រឹក្សាក្រសួងព័ត៌មាន និងជាប្រធាននាយកដ្ឋានសោតទស្សន៍នៃអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍នៃក្រសួងព័ត៌មាន | សមាជិក |
| ១៣-លោក | **សុទ្ធ ធី** | ប្រធាននាយកដ្ឋានឯកសារអេឡិចត្រូនិកនិងព័ត៌មានវិទ្យានៃអគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤-លោក | **ឆុន ចាសនា** | ប្រធាននាយកដ្ឋានបច្ចេកទេស វិទ្យុជាតិកម្ពុជា | សមាជិក |
| ១៥-លោក | **ថោ សេដ្ឋាឧត្តម** | អនុប្រធាននាយកដ្ឋានផែនការ គណនេយ្យនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងព័ត៌មាន | សមាជិក។ |

**ប្រការ២ .-**

ក្រុមការងារបច្ចេកទេសនេះមានភារកិច្ចដូចខាងក្រោម៖

- រៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ (National Digital TV Platform) ដើម្បីដោះស្រាយបន្ទារប្រេកង់700MHz សម្រាប់វិស័យទូរគមនាគមន៍ និងផ្លាស់ប្តូរការផ្សាយទូរទស្សន៍ពីប្រព័ន្ធអាណាឡូកទៅជាប្រព័ន្ធឌីជីថលឱ្យបានទាន់ពេលវេលា ដើម្បីធ្វើសមាហរណកម្មទូរទស្សន៍ឌីជីថលកម្ពុជាទៅក្នុងតំបន់ និងនៅលើពិភពលោក
- រៀបចំផែនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថ្នាលទូរទស្សន៍ឌីជីថលជាតិដោយសិក្សាលម្អិតអំពីការចំណាយសម្រាប់វិនិយោគរយៈពេលបីឆ្នាំដំបូង(២០២១-២០២៣) និងរៀបចំលើកសំណើចំណាយសម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថ្នាលទូរទស្សន៍ឌីជីថលជាតិ នៅតាមដំណាក់កាលនីមួយៗតាមផែនការដែលបានគ្រោងទុក
- ប្រមូលជាតុចូលពីក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធរៀបចំថ្នាលទូរទស្សន៍ឌីជីថលជាតិ និងសម្របសម្រួលជាមួយក្រុមហ៊ុនឯកជនដែលពាក់ព័ន្ធធ្វើការផ្លាស់ប្តូរការផ្សាយទូរទស្សន៍ពីប្រព័ន្ធអាណាឡូកទៅជាប្រព័ន្ធឌីជីថលឱ្យបានប្រព្រឹត្តទៅដោយភាពរលូន និងទទួលបានជោគជ័យ
- រៀបចំធ្វើសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធនានា និងវិស័យឯកជន ព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋឱ្យបានជ្រួតជ្រាប និងយល់ច្បាស់អំពីអត្ថប្រយោជន៍ និងផែនការរៀបចំហេដ្ឋារចនាសម្ព័ន្ធថ្នាលទូរទស្សន៍ឌីជីថលជាតិ ដើម្បីធ្វើការផ្លាស់ប្តូរការផ្សាយទូរទស្សន៍ពីប្រព័ន្ធអាណាឡូកទៅជាប្រព័ន្ធឌីជីថល
- បើកវគ្គបណ្តុះបណ្តាលមន្ត្រីអង្គភាពជំនាញពាក់ព័ន្ធ គ្រូបង្គោលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឱ្យបានយល់ដឹង និងមានសមត្ថភាពប្រើប្រាស់ឧបករណ៍បំប្លែងស៊ីញ៉ាល់ទូរទស្សន៍ឌីជីថល STB (Set Top-Box) ដើម្បីជួយណែនាំដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យចេះប្រើប្រាស់។

**ប្រការ៣ ..**

ក្រុមការងារបច្ចេកទេសមានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិ និងអន្តរជាតិមកចូលរួមផ្តល់យោបល់បន្ថែមលើការរៀបចំផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្សាយទូរទស្សន៍ឌីជីថលជាតិ ហើយមានសិទ្ធិបង្កើតក្រុមការងារតាមតម្រូវការចាំបាច់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមការងារបច្ចេកទេស និងអាចសហការ ឬស្នើឱ្យមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានាតាមតម្រូវការជាក់ស្តែង។

**ប្រការ៤ ..**

ធ្វើរបាយការណ៍អំពីលទ្ធផលការងារដែលបានអនុវត្តនៅតាមដំណាក់កាលនីមួយៗជូនរាជរដ្ឋាភិបាល។

**ប្រការ៥ ..**

ក្រុមការងារបច្ចេកទេសនេះ មានសិទ្ធិប្រើត្រារបស់ក្រសួងព័ត៌មាន។

**ប្រការ៦ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ